00822610

E215

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 07 / 2012
ម៉ោង (Time/Heure): 12:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ៖ | ចៅក្រម **និល ណុន** ជាប្រធាន |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ៖ | ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១២ |
| ភាសាដើម៖ | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ៖ | សាធារណៈ |

# សេចក្ដីសម្រេចលើការចាត់តាំងអ្នកជំនាញ

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា
អៀង សារី
ខៀវ សំផន

**សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE

អាង ឧត្តម
Michael G. KARNAVAS
គង់ សំអុន
Jacques VERGÈS
Arthur VERCKEN
Anta GUISSÉ

## ១. សេចក្ដីផ្ដើម

១. សេចក្ដីសម្រេចនេះ ត្រូវបានចេញអនុលោមតាមវិធាន ៣១(៣) នៃវិធានផ្ទៃក្នុង ហើយពាក់ព័ន្ធនឹងស្ថានភាព និងការចាត់តាំងអ្នកជំនាញមួយចំនួនដែលភាគីបានស្នើសុំឱ្យមកផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/១។

## ២. ប្រវត្តិនីតិវិធី

២. អនុតាមតាមវិធាន ៣១ នៃវិធានផ្ទៃក្នុង និងដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញា មេធាវីការពារក្ដី និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី បានស្នើសុំឱ្យអ្នកជំនាញមួយចំនួនមកផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/១[១]។ ក្រុមមេធាវីការពារក្ដីបានជំទាស់ទៅលើឈ្មោះអ្នកជំនាញនានាដែលសហព្រះរាជអាជ្ញា និងដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំនោះ[២]។ នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ និងថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះ

---

[១] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ឯកសារ E9; “បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់ទី១ ទី២ ទី៣ក ទី៤ និង ទី៥” ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឯកសារ E9/4 និង “ឧបសម្ព័ន្ធ ២៖ បញ្ជីឈ្មោះអ្នកជំនាញរបស់ ក.ស.ព” E9/4.2; “បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្ដឹងរដ្ឋប្បវេណី របស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដោយអនុលោមវិធាន ៨០ រួមទាំងឧបសម្ព័ន្ធសម្ងាត់១ ២ក ២ខ ៣ក ៣ខ និង ៤” ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/3 និង “ឧបសម្ព័ន្ធ ៤៖ បញ្ជីឈ្មោះអ្នកជំនាញដែលត្រូវបានស្នើ [សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី]” ឯកសារ E9/4/3.6; “បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានស្នើសុំដោយភាគី ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/4 (នួន ជា) និង “ឧបសម្ព័ន្ធ ក៖ បញ្ជីឈ្មោះសាក្សីដែលភាគីមានបំណងស្នើសុំឱ្យកោះហៅ (សម្រាប់អ្នកដែលមិនស្នើសុំនូវវិធានការការពារ) - ក្រុមមេធាវីការពារក្ដី នួន ជា” ឯកសារ E9/4/4.4 និង “ឧបសម្ព័ន្ធ ខ៖ បញ្ជីឈ្មោះអ្នកជំនាញដែលត្រូវបានស្នើ - ក្រុមមេធាវីការពារក្ដី នួន ជា” ឯកសារ E9/4/4.2; “បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញរបស់មេធាវីការពារក្ដីអ្នកស្រី អៀង ធីរិទ្ធ” ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/5; និង “បញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ” ថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/6 (ខៀវ សំផន) និង “ឧបសម្ព័ន្ធ ២៖ បញ្ជីឈ្មោះអ្នកជំនាញដែលភាគីមានបំណងស្នើសុំឱ្យកោះហៅ - ខៀវ សំផន” ឯកសារ E9/4/6.1; “ឧបសម្ព័ន្ធ៖ បញ្ជីឈ្មោះអ្នកជំនាញដែលភាគីមានបំណងស្នើសុំឱ្យកោះហៅ - អៀង សារី” ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/2.2។

[២] “ការជំទាស់ជាបឋមរបស់លោក អៀង សារី ចំពោះសំណើសុំអ្នកជំនាញរបស់ ក.ស.ព និង សំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមទៀតក្នុងរយៈពេល ៣០ ថ្ងៃ” ថ្ងៃទី ២៤ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/9 (អៀង សារី) (ដែលជំទាស់ទៅនឹងការស្ដាប់សក្ខីកម្មអ្នកជំនាញមួយចំនួនរួមមាន អ្នកស្រី Elizabeth BECKER, លោក David CHANDLER, អ្នកស្រី Anne

សាលាដំបូងបានជូនដំណឹងទៅភាគីពីចេតនារបស់ខ្លួនក្នុងការស្តាប់សក្ខីកម្មអ្នកជំនាញមួយចំនួនក្នុងចំណោមអ្នកជំនាញទាំងនេះ ក្នុងសំណុំរឿង ០០២/១ រួមទាំងអ្នកជំនាញដែលភាគីបានស្នើសុំក្នុងនោះមាន លោក David CHANDLER (លេខសម្គាល់ TCE-11), អ្នកស្រី Anne GUILLOU (លេខសម្គាល់ TCE-27), លោក Benedict KIERNAN (លេខសម្គាល់ TCE-38), លោក Henri LOCARD (លេខសម្គាល់ TCE-41), លោក អ៊ា ម៉េងទ្រី (លេខសម្គាល់ TCE-44), លោក Philip SHORT (លេខសម្គាល់ TCE-65) និង អ្នកស្រី Elizabeth BECKER (លេខសម្គាល់ TCE-80)[៣]។ ដើម្បីជួយសម្រួលក្នុងការរៀបចំផែនការ និងដោយសារតែអ្នកជំនាញទាំងអស់នេះរស់នៅឯបរទេសនោះ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសរួចហើយពីកាលបរិច្ឆេទសម្រាប់ឱ្យអ្នកជំនាញទាំងនោះ មកផ្តល់សក្ខីកម្ម[៤]។

៣. នៅថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានពន្យារពេលដោយមិនកំណត់សម្រាប់អ្នកស្រី Anne GUILLOU ក្នុងការមកផ្តល់សក្ខីកម្ម ដោយសារអ្នកជំនាញរូបនេះពាក់ព័ន្ធ

---

GUILLOU, លោក Ben KIERNAN, លោក Henri LOCARD, លោក អ៊ា ម៉េងទ្រី និង លោក Philip SHORT); "ការជំទាស់បឋមរបស់លោក អៀង សារី ទៅនឹងសំណើសុំអ្នកជំនាញរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមក្នុងរយៈពេល ៣០ ថ្ងៃ" ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/3/1 (អៀង សារី); "សេចក្តីជំទាស់ទៅនឹងការចូលខ្លួនរបស់អ្នកជំនាញមួយចំនួន" ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/10 (ខៀវ សំផន) និង "សេចក្តីបញ្ជាក់របស់អ្នកស្រី អៀង ធីរិទ្ធ អំពីចេតនាជំទាស់ទៅនឹងសាក្សី និងអ្នកជំនាញដែលមានឈ្មោះនៅក្នុងបញ្ជីឈ្មោះសាក្សីរបស់សហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និង នួន ជា" ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/11 (អៀង ធីរិទ្ធ)។ ដោយសារសក្ខីកម្មរបស់សាក្សីជំនាញលោក Ewa TABEAU ដែលស្នើឡើងដោយភាគី មិនត្រូវបានចាត់ទុកថា ពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿង ០០២/១ ហេតុនេះ សេចក្តីសម្រេចលើការជំទាស់របស់ អៀង សារី ពាក់ព័ន្ធនឹងអ្នកជំនាញរូបនេះ (ឯកសារ E9/4/8) ក៏ត្រូវបានពន្យារទៅពេលក្រោយដែរ។

[៣] "ឧបសម្ព័ន្ធសម្ងាត់ ក៖ ផ្នែកមួយនៃបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់សវនាការដំណាក់កាលដំបូងនៃសំណុំរឿង ០០២" ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ ឯកសារ E131/1.1; "សាក្សី ដើម្បបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/១" ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E172 (ដោយបន្ថែមលោក Philip SHORT (លេខសម្គាល់ TCE-65) នៅក្នុងបញ្ជី និងបានពន្យារពេលស្តាប់សក្ខីកម្មអ្នកស្រី Anne GUILLOU (លេខសម្គាល់ TCE-27))។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញបានទទួល *ជីវប្រវត្តិវិជ្ជាជីវៈ* របស់លោក David CHANDLER, លោក Henri LOCARD, លោក Philip SHORT និងអ្នកស្រី Elizabeth BECKER និងបានចែកចាយដល់ភាគីនានារួចរាល់ហើយ។

[៤] "ព័ត៌មានបច្ចុប្បន្នភាពទាក់ទិននឹងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មអ្នកជំនាញដែលភាគីបានស្នើសុំ" ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ E172/24។

តែទៅលើតួនាទីរបស់ជនជាប់ចោទ អៀង ធីរិទ្ធ បន្ទាប់ពីជនជាប់ចោទរូបនេះត្រូវបានបំបែកចេញពីការជំនុំជម្រះនោះ[៥]។ នៅថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ សហព្រះរាជអាជ្ញាបានលើកឡើងថា ខ្លួនមើលមិនឃើញថា មានវិធីណាមួយដែលមានប្រសិទ្ធភាព និងអាចសម្រេចតាមពេលកំណត់ក្នុងការបង្ខំឲ្យលោក អ៊ា ម៉េងទ្រី មកផ្តល់សក្ខីកម្មនោះទេ[៦]។ ដោយសារពុំមានសំណើផ្សេងទៀតដើម្បីជំរុញឲ្យមានការខិតខំប្រឹងប្រែងក្នុងការស្តាប់សក្ខីកម្មអ្នកជំនាញរូបនេះ អង្គជំនុំជម្រះបានសម្រេចថានឹងមិនស្តាប់សក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង ០០២/១ ទេ។ នៅថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ បន្ទាប់ពីមានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការទទួលបានសក្ខីកម្មរបស់លោក Benedict KIERNAN មក អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ដោយសារគាត់មិនព្រមសហការ និងដោយសារពុំមានគំរូអនុវត្តន៍ណាមួយដើម្បីបង្ខំឲ្យអ្នកជំនាញដែលមានចិត្តរួញរា ចូលមកផ្តល់សក្ខីកម្មទេនោះ អង្គជំនុំជម្រះសាលាដំបូងនឹងមិនបន្តការព្យាយាមដើម្បីទទួលបានសក្ខីកម្មរបស់គាត់ក្នុងសំណុំរឿង ០០២/១ ទេ[៧]។ ចុងក្រោយ និងបន្ទាប់ពីបានពិនិត្យឡើងវិញទៅលើសាក្សី និងអ្នកជំនាញទាំងអស់ដែលភាគីបានស្នើសុំ ដើម្បីជាប្រយោជន៍ដល់ការធានាឲ្យដំណើរការសវនាការបានឆាប់រហ័សនោះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចផ្អាកការស្តាប់សក្ខីកម្មអ្នកជំនាញលោក Henri LOCARD ដោយសារសក្ខីកម្មរបស់គាត់ពាក់ព័ន្ធតិចតួចនឹងសំណុំរឿង ០០២/១[៨]។

៤. សេចក្តីសម្រេចនេះធ្វើការសម្រេចទៅលើការជំទាស់នានាចំពោះសក្ខីកម្មរបស់អ្នកជំនាញដទៃទៀតដែលភាគីបានស្នើសុំ ឬចំពោះគុណសម្បត្តិរបស់អ្នកទាំងនោះជាអ្នកជំនាញ អនុលោមតាមវិធាន ៣១ នៃវិធានផ្ទៃក្នុង។ ដោយសារភាគីបានស្នើសុំឲ្យស្តាប់សក្ខីកម្មបុគ្គលទាំងនេះមុនពេលបំបែក

---

៥ សេចក្តីសម្រេចលើសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ ថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E138; "សាក្សី ដើម្បបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/១" ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E172 ទំព័រ ៦ ("លេខសម្គាល់ TCE-27")។

៦ "សេចក្តីជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានាទាក់ទងនឹងសក្ខីកម្មរបស់សាក្សី TCE-38 និង TCE-44" ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០១២ ឯកសារ E166/1 កថាខណ្ឌ ៨។

៧ "សក្ខីកម្មរបស់ Benedict KIERNAN ដែលភាគីបានស្នើសុំនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង" ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១២ ឯកសារ E166/1/4។

៨ "ព័ត៌មានបច្ចុប្បន្នភាពទាក់ទិននឹងការកំណត់កាលបរិច្ឆេទស្តាប់សក្ខីកម្មអ្នកជំនាញដែលភាគីបានស្នើសុំ" ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ ឯកសារ E172/24។

នីតិវិធីនៃសំណុំរឿង ០០២ ទៅជាសវនាការមួយចំនួន និងដើម្បីបញ្ចៀសការហៅសាក្សី ឬអ្នកជំនាញ ទាំងនេះមកធ្វើសក្ខីកម្មឡើងវិញដោយមិនចាំបាច់នោះ អង្គជំនុំជម្រះធ្លាប់បានសម្រេចរួចមកហើយថា អ្នកទាំងនោះអាចនឹងត្រូវសាកសួររាល់បញ្ហានានាទៅតាមការយល់ដឹង ឬជំនាញរបស់ខ្លួន ដែលពាក់ព័ន្ធនឹងដីកាដំណោះស្រាយទាំងមូលក្នុងសំណុំរឿង ០០២[៩]។ ក្នុងគោលបំណងដើម្បីធានាឱ្យមានសវនាការឆាប់រហ័ស និងដោយសារការអនុញ្ញាតឱ្យសួរសំណួរហួសពីវិសាលភាពនៃសំណុំរឿង ០០២/១ ដែលជាញឹកញយនាំឱ្យមានការសួរដេញដោលវែងឆ្ងាយនោះ អង្គជំនុំជម្រះសូមរម្លឹកដល់ភាគីថា ការសួរដេញដោលរបស់ខ្លួនគួរតែផ្តោតជាសំខាន់ត្រឹមតែបញ្ហាសាច់រឿងក្នុងសំណុំរឿង ០០២/១ បានហើយ។ ការសាកសួរបញ្ហានានាដែលហួសពីវិសាលភាពនេះ គួរតែត្រូវកំហិតត្រឹមតែចំណុចណាដែលភាគីយល់ថា អ្នកជំនាញ ឬសាក្សីនោះមានគុណវុឌ្ឍិដោយឡែកក្នុងការឆ្លើយតបលើចំណុចនោះតែប៉ុណ្ណោះ[១០]។ អង្គជំនុំជម្រះក៏ផ្តល់សិទ្ធិដល់សហព្រះរាជអាជ្ញាឱ្យទទួលខុសត្រូវដឹកនាំការសួរសំណួររបស់ខ្លួនក្នុងសវនាការ អនុលោមតាមវិធាន ៩១ និង ៩១*ស្ទួន*។

## ៣. សារណា

៥. សហព្រះរាជអាជ្ញាបញ្ជាក់ថា លោក David CHANDLER គឺជាសាស្ត្រាចារ្យចូលនិវត្ត (Emeritus Professor) នៅសាកលវិទ្យាល័យ Monash និងបានទទួលសញ្ញាប័ត្រពីសាកលវិទ្យាល័យ Harvard, Yale និង Michigan។ គាត់ជាប្រវត្តិវិទូមួយរូបក្នុងចំណោមប្រវត្តិវិទូ ដ៏ឆ្នើមស្តីពីប្រវត្តិសាស្ត្រកម្ពុជា និងជាអ្នកជំនាញលើបញ្ហាមន្ទីរ ស២១ ដែរ ដោយបានធ្វើការវិភាគយ៉ាងទូលំទូលាយទៅលើកំណត់ហេតុនានារបស់អ្នកទោសនៅមន្ទីរនេះ។ គាត់បានកាន់តំណែងជាមន្ត្រីសេវាកម្មបរទេសនៃសហរដ្ឋអាមេរិក (United States Foreign Service Officer) ពីឆ្នាំ ១៩៥៨ ដល់ឆ្នាំ ១៩៦៦ និងបានបំពេញការងារនៅទីក្រុងភ្នំពេញពីឆ្នាំ ១៩៦០ ដល់ ១៩៦២។ គាត់និយាយភាសាខ្មែរបានយ៉ាងស្ទាត់ជំនាញ និងបាននិពន្ធដោយខ្លួនឯងផង និងរួមជាមួយអ្នកនិពន្ធដទៃទៀត

---

[៩] ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារ E124; "ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះដំណាក់កាលដំបូងនៅក្នុងសំណុំរឿង ០០២ ដែលបានធ្វើការកែប្រែបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានចេញសេចក្តីសម្រេចអំពីបញ្ហាសម្បទារបស់ អៀង ធីរិទ្ធ ក្នុងការចូលរួមសវនាការ" ដែលបានដាក់ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារ E124/7.2។

[១០] សេចក្តីជូនដំណឹងនេះនឹងត្រូវផ្តល់ជូនអ្នកជំនាញ *តាមរយៈ* អង្គភាពគាំពារសាក្សី និងអ្នកជំនាញ តាមពេលវេលាសមស្រប។

ផងនូវស្នាដៃនានាដូចជា សៀវភៅ ឯកសារសិក្សាស្រាវជ្រាវ និងសំណេរមួយចំនួនដែលមិនបានបោះពុម្ពផ្សាយ ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រប្រទេសកម្ពុជា និងពួកខ្មែរក្រហម រួមទាំង៖ *សម្លេងពីមន្ទីរ ស២១ (Voices from S-21)* (ឆ្នាំ ២០០០) (ឯកសារ D108/50/1.4.6) *បងទីមួយ (Brother Number One)* (ឆ្នាំ ១៩៩២) (ឯកសារ E3/17) *សោកនាដកម្មក្នុងប្រវត្តិសាស្ត្រកម្ពុជា (The Tragedy of Cambodian History)* (ឆ្នាំ ១៩៩១) (ឯកសារ D108/50/1.75) និង *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា* (ឆ្នាំ ១៩៨៣) (ឯកសារ D366/7.1.69)។ គាត់ក៏បានចូលរួមកែសម្រួលសៀវភៅដែលមានចំណងជើងថា *ប៉ុល ពត រៀបចំផែនការទៅអនាគត (Pot Plans for the Future)* (ឯកសារ E3/8) ដែរ។ គាត់ធ្លាប់បានចូលរួមផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីជំនាញនៅចំពោះអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ រួចមកហើយ[១១]។ សហព្រះរាជអាជ្ញាបានស្នើសុំសួរដេញដោលរូបគាត់ពាក់ព័ន្ធនឹង ប្រភព ការបង្កើត និងការវិវត្តន៍នៃគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា (ប.ក.ក) ដោយផ្តោតជាពិសេសទៅលើគោលនយោបាយនៃការកំណត់អត្តសញ្ញាណ និងការកម្ទេចខ្មាំង តួនាទីរបស់មេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក ក្នុងការបង្កើតគោលនយោបាយទាំងនេះ ប្រតិបត្តិការនៅមន្ទីរសន្តិសុខ ស២១ រចនាសម្ព័ន្ធគ្រប់គ្រងពីលើមន្ទីរ ស២១ និងទំនាក់ទំនងរវាងមន្ទីរ ស២១ និង មេដឹកនាំជាន់ខ្ពស់នៃ ប.ក.ក (រួមទាំង នួន ជា ផង) និង អំណាចតាមផ្លូវច្បាប់ និងជាក់ស្តែង របស់ជនជាប់ចោទ[១២]។

៦. មេធាវីការពារក្តី នួន ជា យល់ស្របថា លោក David CHANDLER គឺជាអ្នកជំនាញដ៏ឆ្នើមស្តីពីប្រទេសកម្ពុជា តែបានចោទប្រកាន់ថា គាត់បានបដិសេធថា ពុំមានទំនាក់ទំនងដ៏រឹងមាំរវាងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងមេដឹកនាំខ្មែរក្រហម ហេតុនេះហើយ គាត់អាចផ្តល់ការយល់ដឹងស៊ីជម្រៅទៅលើរចនាសម្ព័ន្ធបញ្ជាការផ្សេងទៀតក្នុងរបបខ្មែរក្រហម[១៣]។

---

[១១] "ឧបសម្ព័ន្ធ ១៖ សេចក្តីសង្ខេប អំពីសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដោយមានចំណុចនៃដីកាដំណោះស្រាយ - ក.ស.ព" ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/13.1 ("ឧបសម្ព័ន្ធ ១") ទំព័រ ១៤៨-១៥០។

[១២] ឧបសម្ព័ន្ធ ១ (ដដែល) ទំព័រ ១៤៨-១៥០។

[១៣] "សេចក្តីសង្ខេបអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំ" ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/10 (នួន ជា) និង "ឧបសម្ព័ន្ធ ឃ៖ សេចក្តីសង្ខេបរបស់សាក្សីជាមួយនឹងចំណុចនៃការចោទប្រកាន់" ឯកសារ E9/10.1 ទំព័រ ៣២; "សេចក្តីសង្ខេបបច្ចុប្បន្នភាពអំពីសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី" ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E93/4 និង "បញ្ជីបឋម/សេចក្តីសង្ខេបអំពីសាក្សី - ក្រុមមេធាវីការពារក្តី នួន ជា" ឯកសារ E93/4.3 ទំព័រ ២២ (ជាភាសាអង់គ្លេស)។

៧. មេធាវីការពារក្តី អៀង សារី បានបដិសេធមិនព្រមហៅលោកសាស្ត្រាចារ្យ CHANDLERថាជាអ្នកជំនាញទេ ដោយសំអាងថា ការងាររបស់គាត់មិនអាចទុកចិត្តបាន ដោយសារនៅក្នុងសៀវភៅដំបូងរបស់គាត់ពុំមានភាពសុក្រឹត្យ និងថា ការចូលរួមរបស់គាត់ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") បានធ្វើឱ្យគាត់មិនមានភាពឯករាជ្យគ្រប់គ្រាន់ និងមានភាពលម្អៀងនៅក្នុងការផ្តល់សក្ខីកម្មក្នុងនាមជាអ្នកជំនាញ[១៤]។

៨. សហព្រះរាជអាជ្ញាបានបញ្ជាក់ថា លោក Philip SHORT បានសិក្សានៅសាកលវិទ្យាល័យ Cambridge និងបានបំពេញការងារជាអ្នកសារព័ត៌មានឯករាជ្យនៅទ្វីបអាហ្វ្រិកពីឆ្នាំ ១៩៦៧ ដល់ឆ្នាំ ១៩៧៣។ បន្ទាប់មក គាត់បានបម្រើការងារនៅសាជីវកម្មផ្សាយសម្លេងចក្រភពអង់គ្លេស ("BBC") ដែលនៅទីនោះ គាត់បានបំពេញការងារជាអ្នកឆ្លើយឆ្លងព័ត៌មានបរទេសរយៈពេល ២៥ ឆ្នាំ។ នៅឆ្នាំ ១៩៩៧ គាត់បានបញ្ចប់ការងារជាអ្នកឆ្លើយឆ្លងព័ត៌មានរបស់ BBC ប្រចាំក្រុងវ៉ាស៊ីងតោន ហើយបន្ទាប់មក គាត់បានបង្រៀនមុខវិជ្ជានយោបាយប្រៀបធៀបនៅសាកលវិទ្យាល័យ Iowa។ នាពេលថ្មីៗនេះ គាត់ជាអ្នកនិពន្ធឯករាជ្យ ដោយបានសរសេរសៀវភៅមួយចំនួន ក្នុងនោះមាន៖ *ប៉ុល ពត៖ ប្រវត្តិសាស្ត្រនៃសុបិន្តអាក្រក់មួយ (Pol Pot: The History of a Nightmare)* (ឆ្នាំ ២០០៤) (ឯកសារ E3/9) *ម៉ៅ៖ ជីវិតមនុស្សម្នាក់ (Mao: A Life)* (ឆ្នាំ ២០០០) និង *នាគ និងខ្លាឃ្មុំ៖ នៅក្នុងប្រទេសចិន និងរុស្ស៊ីនាពេលបច្ចុប្បន្ន (The Dragon and The Bear: Inside China and Russia Today)* (ឆ្នាំ ១៩៨២)។ ក្នុងការស្រាវជ្រាវដើម្បីសរសេរសៀវភៅរបស់គាត់ស្តីពី ប៉ុល ពត និងរបបកម្ពុជាប្រជាធិបតេយ្យ (POL Pot and Democratic Kampuchea) ("DK") គាត់បានធ្វើការសម្ភាសន៍ជាច្រើនជាមួយបណ្តាមេដឹកនាំជាន់ខ្ពស់ ប.ក.ក រួមទាំង ខៀវ សំផន, អៀង សារី និង សុន សេន រួមទាំងកម្មាភិបាលជាន់ខ្ពស់ជាច្រើននាក់ទៀត ដែលត្រូវបានការិយាល័យសហចៅក្រមស៊ើបអង្កេត ("ក.ស.ច.ស") ស្តាប់ចម្លើយរួចហើយ។ ជនជាប់ចោទ ខៀវ សំផន បានបញ្ចេញមតិយ៉ាងច្រើនទៅលើសៀវភៅនេះ រួមទាំងការ

---

[១៤] "ការជំទាស់ជាបឋមរបស់លោក អៀង សារី ចំពោះសំណើសុំអ្នកជំនាញរបស់ ក.ស.ព និង សំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមទៀតក្នុងរយៈពេល ៣០ ថ្ងៃ" ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/9 (អៀង សារី) កថាខណ្ឌ ១-១៤ និង ២០-២២ (ដោយបានលើកឡើងជាទឡ្ហីករណ៍ថា លោក David CHANDLER គឺជាទីប្រឹក្សាជំនួយដល់ DC-Cam ដែលធ្វើការគាំទ្រដល់សេចក្តីសន្និដ្ឋានមុនសម្រេចសេចក្តីថា អំពើប្រល័យពូជសាសន៍ដែលបានកើតឡើងនៅប្រទេសកម្ពុជា ជាជាងការស្វែងរកការពិតអំពីព្រឹត្តិការណ៍ចន្លោះឆ្នាំ ១៩៧៥-៧៩)។

វិភាគរបស់លោក Philip SHORT ចំពោះការបោសសម្អាតរបស់ ប.ក.ក នៅក្នុងសៀវភៅដែលមានចំណងជើងថា *ពិចារណាអំពីប្រវត្តិសាស្ត្រកម្ពុជា ពីសម័យដើមរហូតដល់សម័យកម្ពុជាប្រជាធិបតេយ្យ (Considerations on the History of Cambodia)* (ឯកសារ E3/16)។ លោក Philip SHORT ក៏បានជួប ប៉ុល ពត ដោយផ្ទាល់ក្នុងឆ្នាំ ១៩៧៧ នៅពេល ប៉ុល ពត បំពេញទស្សនកិច្ចនៅទីក្រុងប៉េកាំង[១៥]។

៩. សហព្រះរាជអាជ្ញាស្នើសុំស្ដាប់សក្ខីកម្មលោក Philip SHORT ស្ដីពីប្រវត្តិ ប.ក.ក មុនឆ្នាំ ១៩៧៥ ការបង្កើតគោលនយោបាយ ប.ក.ក រួមទាំងការប្រើអំពើហិង្សាប្រឆាំងនឹងខ្មាំង ការជម្លៀសប្រជាជនដោយបង្ខំចេញពីទីប្រជុំជន ការបង្កើតសហករណ៍ ការប្រើប្រាស់កម្លាំងពលកម្មដោយបង្ខំ និងការគាបសង្កត់ផ្នែកសាសនា រចនាសម្ព័ន្ធអំណាច និងដំណើរការ ប.ក.ក កម្ពុជាប្រជាធិបតេយ្យ និងកងទ័ពបដិវត្តន៍កម្ពុជាក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងអំណាចតាមផ្លូវច្បាប់ និងជាក់ស្ដែងរបស់ជនជាប់ចោទ[១៦]។ មេធាវីការពារក្ដី នួន ជា យល់ស្របថា ពាក់ព័ន្ធនឹងជំនាញរបស់គាត់លើប្រធានបទនេះ លោក Philip SHORT អាចផ្ដល់សក្ខីកម្មជាទូទៅបាន ទាក់ទិននឹង ប.ក.ក និងកិច្ចការទូទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[១៧]។

១០. សហព្រះរាជអាជ្ញាបានបញ្ជាក់ថា អ្នកស្រី Elizabeth BECKER គឺជាអ្នកនិពន្ធ និងជាអ្នកសារព័ត៌មាន ដែលបានប្រមូលព័ត៌មានស្ដីពីកិច្ចការអន្តរជាតិក្នុងឋានៈជាអ្នកឆ្លើយឆ្លងព័ត៌មានឲ្យកាសែត *The New York Times* និង *The Washington Post* និងជានិពន្ធនាយកជាន់ខ្ពស់ផ្នែកកិច្ចការបរទេស (Senior Foreign Editor) ប្រចាំវិទ្យុជាតិសាធារណៈ (National Public Radio) (សហរដ្ឋអាមេរិក)។ អ្នកស្រីបានចាប់ផ្ដើមអាជីពរបស់ខ្លួនជាអ្នកឆ្លើយឆ្លងព័ត៌មានពេលសង្គ្រាមនៅឆ្នាំ ១៩៧២ ដោយបានធ្វើសេចក្ដីរាយការណ៍ស្ដីពីជម្លោះនៅប្រទេសកម្ពុជា ហើយបន្ទាប់មក

---

[១៥] ឧបសម្ព័ន្ធ ១ ឯកសារ E9/13.1 ទំព័រ ៣៧-៣៩។

[១៦] ឧបសម្ព័ន្ធ ១ ឯកសារ E9/13.1 ទំព័រ ៣៧-៣៩។

[១៧] "សេចក្ដីសង្ខេបអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលភាគីបានស្នើសុំ" ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/10 និង "ឧបសម្ព័ន្ធ ឃ៖ សេចក្ដីសង្ខេបអំពីសាក្សីជាមួយនឹងចំណុចនៃការចោទប្រកាន់" ឯកសារ E9/10.1 (នួន ជា) ទំព័រ ១៨៤; "សេចក្ដីសង្ខេបបច្ចុប្បន្នភាពអំពីសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី" ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E93/4 និង "បញ្ជីបឋម/សេចក្ដីសង្ខេបអំពីសាក្សី - ក្រុមមេធាវីការពារក្ដី នួន ជា" ឯកសារ E93/4.3 ទំព័រ ១២០ (ជាភាសាអង់គ្លេស)។

គាត់បានប្រមូលព័ត៌មានស្ដីពីព្រឹត្តិការណ៍នានានៅប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍រយៈពេលជាច្រើនឆ្នាំ។ នៅពេលអ្នកស្រីបំពេញការងារនៅទីក្រុងប៉ារីសពីឆ្នាំ ១៩៨៦ ដល់ឆ្នាំ ១៩៩០ អ្នកស្រីបានប្រមូលព័ត៌មានស្ដីពីបញ្ហាជនភៀសខ្លួន និងសិទ្ធិមនុស្ស និងការចរចាស្វែងរកសន្តិភាពដែលធ្វើឱ្យមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ ១៩៩១។ អ្នកស្រីមានសញ្ញាប័ត្រផ្នែកសិក្សាអំពីអាស៊ីខាងត្បូងពីសាកលវិទ្យាល័យ Washington និងជាសាស្ត្រាចារ្យអមធ្វើការមិនពេញម៉ោងនៅសាកលវិទ្យាល័យ Georgetown។ អ្នកស្រីជាសាស្ត្រាចារ្យពេញម៉ោងបង្រៀនមុខវិជ្ជាមួយចំនួនរួមមាន បញ្ហានៅទ្វីបអាស៊ី សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍អន្តរជាតិ ហើយអ្នកស្រីធ្លាប់បានផ្ដល់សក្ខីកម្មនៅចំពោះមុខសភាសហរដ្ឋអាមេរិក រដ្ឋសភាបារាំង និងអង្គការសហប្រជាជាតិ។ អ្នកស្រីជាសមាជិកនៃក្រុមប្រឹក្សាទំនាក់ទំនងការបរទេស ដែលជាអង្គការអាមេរិកាំងមិនប្រកាន់បក្សពួក និងមិនស្វែងរកប្រាក់ចំណេញ ហើយអ្នកស្រីបានទទួលពានរង្វាន់ duPont-Columbia ចំនួនពីរសម្រាប់ការរាយការណ៍ពីការបោះឆ្នោតតាមបែបប្រជាធិបតេយ្យជាលើកដំបូងនៅអាហ្វ្រិកខាងត្បូង និងអំពើប្រល័យពូជសាសន៍នៅរ៉ាវ៉ាន់ដា។ អ្នកស្រីជាអ្នកនិពន្ធសៀវភៅ *នៅពេលដែលសង្គ្រាមផុតរលត់ទៅ៖ កម្ពុជានិងបដិវត្តន៍ខ្មែរក្រហម (When the war was over: Cambodia and the Khmer Rouge Revolution)* (ឆ្នាំ ១៩៨៦) ដែលនៅតែជាសៀវភៅមួយដែលបានរៀបរាប់រឿងរ៉ាវពីរបបខ្មែរក្រហមបានល្អជាងគេ (ឯកសារ E3/20) *សង្គ្រាមវៀតណាមរបស់អាមេរិក៖ ប្រវត្តិសាស្ត្របែបពណ៌នា (America's Vietnam War: A Narrative History)* (ឆ្នាំ ១៩៩២) និង *បុប្ផាណា (Bophana)* (ឆ្នាំ ២០១០) ដែលជារឿងរ៉ាវរបស់ជនរងគ្រោះម្នាក់នៅមន្ទីរ ស២១។ នៅចុងឆ្នាំ ១៩៧៨ អ្នកស្រី Elizabeth BECKER គឺជាអ្នកសារព័ត៌មានម្នាក់ក្នុងចំណោមអ្នកសារព័ត៌មានបស្ចិមប្រទេស ៣ នាក់ ដែលបានទទួលការអញ្ជើញឱ្យទៅបំពេញទស្សនកិច្ចនៅកម្ពុជាប្រជាធិបតេយ្យ។ ក្នុងអំឡុងពេលទស្សនកិច្ចនេះ អ្នកស្រីបានធ្វើដំណើរជុំវិញទីក្រុងភ្នំពេញ និងនៅតាមទីជនបទ និងបានទទួលការអនុញ្ញាតដោយកម្រមួយឱ្យសម្ភាស ប៉ុល ពត (ឯកសារ D365/1.1.69)។ កំណត់សម្គាល់របស់អ្នកស្រី BECKER ពីទស្សនកិច្ចនេះ មានក្នុងសំណុំរឿង (ឯកសារ D366/7.1.407, ឯកសារ E3/1171)។ ក្នុងអំឡុងពេលសិក្សាស្រាវជ្រាវ អ្នកស្រីក៏បានសម្ភាសជាមួយ អៀង សារី និង អៀង ធីរិទ្ធ ដែរ (ឯកសារ E3/659)។

១១. សហព្រះរាជអាជ្ញាស្នើសុំការសាកសួរអ្នកស្រី Elizabeth BECKER ស្ដីពីប្រវត្តិ ប.ក.ក និងទំនាក់ទំនងជាមួយសមភាគីវៀតណាមរបស់ខ្លួន របបកម្ពុជាប្រជាធិបតេយ្យ រចនាសម្ព័ន្ធគ្រប់គ្រង

និងដំណើរការក្នុងមជ្ឈិមបក្សនៃ ប.ក.ក និងស្ថាប័ន ប.ក.ក នៅថ្នាក់តំបន់ មនោគមវិជ្ជា និង គោលនយោបាយ ប.ក.ក ការបង្កើតសហករណ៍ដោយបង្ខំ ពលកម្មដោយបង្ខំ និងមន្ទីរសន្តិសុខក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការធ្វើទុក្ខបុកម្នេញទៅលើជនជាតិភាគតិច និងអំណាចតាមផ្លូវច្បាប់ និងជាក់ស្តែងរបស់ជនជាប់ចោទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និង ប.ក.ក។ សហព្រះរាជអាជ្ញានឹងសាកសួរអ្នកស្រីស្តីពីស្ថានភាពនៅក្នុងរបបសាធារណរដ្ឋខ្មែរមុនឆ្នាំ ១៩៧៥ ព្រឹត្តិការណ៍នានាដែលអ្នកស្រីបានឃើញ និងទីកន្លែងនានាដែលអ្នកស្រីបានទៅទស្សនាក្នុងពេលបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជា។ សហព្រះរាជអាជ្ញាក៏ស្នើសុំឱ្យអ្នកស្រីជួយបញ្ជាក់យថាភាពនៃកំណត់ហេតុ និងកំណត់ត្រានៃបទសម្ភាសន៍របស់អ្នកស្រីជាមួយ ប៉ុល ពត (ឯកសារ D365/1.1.69, D366/7.1.407, ឯកសារ E3/1171) និងជាមួយ អៀង សារី (ឯកសារ E3/659)។

១២. មេធាវីការពារក្តី អៀង សារី ជំទាស់នឹងការហៅលោក Philip SHORT និង អ្នកស្រី Elizabeth BECKER ថាជាអ្នកជំនាញ ដោយសំអាងថា ក្នុងនាមជាអ្នកសារព័ត៌មាន ពួកគេពុំមានចំណេះដឹងឯកទេស បទពិសោធន៍ ឬជំនាញ ដែលអាចជួយអង្គជំនុំជម្រះសាលាដំបូង ឱ្យយល់ ឬសម្រេចទៅលើបញ្ហានានាដែលកំពុងមានវិវាទនោះទេ។ មេធាវីការពារក្តីលើកឡើងថា ពួកគេគួរត្រូវចាត់ទុកត្រឹមជាសាក្សីមកបញ្ជាក់អង្គហេតុទើបសមស្រប ឬមិនត្រូវទទួលបានឋានៈជាសាក្សីតែម្តង[១៨]។

១៣. មេធាវីការពារក្តី នួន ជា ក៏បានស្នើដល់អង្គជំនុំជម្រះសាលាដំបូងឱ្យស្តាប់សក្ខីកម្មរបស់អ្នកស្រី Elizabeth BECKER តែក្នុងនាមជាសាក្សីមកបញ្ជាក់អង្គហេតុ។ ប៉ុន្តែ ដោយសារអ្នកស្រីធ្លាប់ធ្វើជាអ្នកឆ្លើយឆ្លងព័ត៌មាននៅក្នុងរបបសាធារណរដ្ឋខ្មែរសម្រាប់កាសែត Washington Post និងត្រូវបានបណ្តេញចេញពីរបបកម្ពុជាប្រជាធិបតេយ្យជាមួយជនបរទេសដទៃទៀតនៅខែ មេសា ឆ្នាំ ១៩៧៥ នោះ មេធាវីការពារក្តីបានលើកឡើងថា អ្នកស្រីអាចផ្តល់ការយល់ដឹងលម្អិតអំពីស្ថានភាពនៅក្នុងរបបសាធារណរដ្ឋខ្មែរមុនឆ្នាំ ១៩៧៥ បាន។ ដោយសារអ្នកស្រីជាអ្នកសារព័ត៌មានម្នាក់ក្នុង

---

[១៨] "ការជំទាស់ជាបឋមរបស់លោក អៀង សារី ចំពោះសំណើសុំអ្នកជំនាញរបស់ ក.ស.ព និង សំណើសុំការអនុញ្ញាតដាក់សារណាបន្ថែមទៀតក្នុងរយៈពេល ៣០ ថ្ងៃ" ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/4/9 (អៀង សារី) កថាខណ្ឌ ១៥-១៦, ៣៣ (ដោយបានលើកទឡ្ហីករណ៍ថា អ្នកស្រី Elizabeth BECKER និង លោក Philip SHORT ដែលជាអ្នកយកព័ត៌មាន ទំនងជាពុំមានសញ្ញាប័ត្រដែលពាក់ព័ន្ធទេ។ អ្នកទាំងពីរគ្រាន់តែបានបោះពុម្ពផ្សាយសៀវភៅពាក់ព័ន្ធតែមួយក្បាលប៉ុណ្ណោះ ហើយក៏មិនចេះនិយាយភាសាខ្មែរទៀត។ ក៏ប៉ុន្តែ បទពិសោធន៍ផ្ទាល់របស់អ្នកស្រី Elizabeth BECKER ទាក់ទិននឹងព្រឹត្តិការណ៍នានានៅកម្ពុជាអនុញ្ញាតឱ្យអ្នកស្រីអាចជួយអង្គជំនុំជម្រះក្នុងនាមជាសាក្សីលើអង្គហេតុបាន)។

ចំណោមអ្នកសារព័ត៌មានអាមេរិកតែពីរនាក់ដែលត្រូវបានអនុញ្ញាតឲ្យមកយកព័ត៌មានអំពីរបបកម្ពុជាប្រជាធិបតេយ្យមួយរយៈខ្លីនៅឆ្នាំ ១៩៧៨ នោះ អ្នកស្រីអាចនឹងផ្ដល់ការយល់ដឹងបន្ថែមទៀតពីស្ថានភាពទូទៅនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ នាឆ្នាំ ១៩៧៨[១៩]។

## ៤. សំអាងហេតុ

### ៤.១. ច្បាប់ជាធរមាន

១៤. អនុលោមតាមវិធាន ៣១(១) និង (៣) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូង អាចរកជំនួយជាមតិយោបល់ពីអ្នកជំនាញអំពី "បញ្ហាដែលយល់ឃើញថាមានសារៈសំខាន់ចាំបាច់ [...] ដល់កិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះ" និងត្រូវចែងឲ្យច្បាស់អំពីភារកិច្ចនៅក្នុងដីការអម។ អនុលោមតាមវិធាន ៨០*ស្ទួន* (២) នៃវិធានផ្ទៃក្នុង "[នៅពេល] អង្គជំនុំជម្រះសាលាដំបូងពិចារណាឃើញថាការស្ដាប់ [...] អ្នកជំនាញ ដែលត្រូវបានស្នើសុំ នឹងមិននាំមកនូវដំណើរការល្អនៃការស្វែងរកយុត្តិធម៌ អង្គជំនុំជម្រះសាលាដំបូងត្រូវបដិសេធសំណើសុំឲ្យកោះហៅបុគ្គលនោះ"។

១៥. តុលាការអន្តរជាតិ និងតុលាការកូនកាត់ផ្សេងទៀត បានចាត់ទុកជាអ្នកជំនាញ ចំពោះបុគ្គលទាំងឡាយណាដែលមានជំនាញពាក់ព័ន្ធ ឬមានចំណេះដឹងឯកទេស ដែលទទួលបានតាមរយៈការអប់រំ បទពិសោធន៍ ឬការបណ្ដុះបណ្ដាលនៅក្នុងវិស័យជំនាញដែលបានស្នើសុំ[២០]។ ចំពោះ

---

[១៩] "សេចក្ដីសង្ខេបអំពីបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានស្នើសុំ" ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារ E9/10 (នួន ជា) និង "ឧបសម្ព័ន្ធ ឃ៖ សេចក្ដីសង្ខេបរបស់សាក្សីជាមួយនឹងចំណុចនៃការចោទប្រកាន់" ឯកសារ E9/10.1 ទំព័រ ១៣-១៤; "សេចក្ដីសង្ខេបបច្ចុប្បន្នភាពអំពីសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណី" ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារ E93/4 និង "បញ្ជីបឋម/សេចក្ដីសង្ខេបអំពីសាក្សី - ក្រុមមេធាវីការពារក្ដី នួន ជា" ឯកសារ E93/4.3 ទំព័រ ១០ (ជាភាសាអង់គ្លេស)។

[២០] រឿងក្ដី *Gacumbitsi ទល់នឹង រដ្ឋអាជ្ញា* សាលដីកាអង្គជំនុំជម្រះតុលាការកំពូល (ICTR-2011-64-A) ថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ២០០៦ កថាខណ្ឌ ៣១។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Milan Martić* សេចក្ដីសម្រេចលើសារណាស្ដីពីរបាយការណ៍របស់អ្នកជំនាញ Pr Smilja Avramov អនុលោមតាមវិធាន ៩៤ស្ទួន អង្គជំនុំជម្រះសាលាដំបូង (IT-95-11-T) ចុះថ្ងៃទី ០៩ ខែ វិច្ឆិកា ឆ្នាំ ២០០៦ កថាខណ្ឌ ៧។ រឿងក្ដី *Nahimana ទល់នឹង រដ្ឋអាជ្ញា* សាលដីកាអង្គជំនុំជម្រះតុលាការកំពូល (ICTR-99-52-A) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ កថាខណ្ឌ ១៩៧-១៩៩។ រឿងក្ដី *រដ្ឋអាជ្ញា ទល់នឹង Pavle Strugar* សេចក្ដីសម្រេចលើញត្តិរបស់ក្រុមមេធាវីការពារក្ដី ប្ដឹងជំទាស់នឹងការទទួលយករបាយការណ៍អ្នកជំនាញរបស់រដ្ឋអាជ្ញា អនុលោមតាមវិធាន ៩៤ស្ទួន អង្គជំនុំជម្រះសាលាដំបូង (IT-01-42-PT) ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០០៤ ទំព័រ ៤ (ជាភាសាអង់គ្លេស)។ រឿងក្ដី

ការដែលគ្រាន់តែថា សាក្សីជំនាញមានការជាប់ពាក់ព័ន្ធពីមុនជាមួយនឹងអង្គការខាងក្រៅណាមួយនោះ ករណីនេះពុំមែនជាការរារាំងមិនអាចឱ្យកោះហៅអ្នកជំនាញរូបនេះមកធ្វើជាអ្នកជំនាញនោះទេ[២១]។ នៅក្នុងក្របខណ្ឌច្បាប់ អ.វ.ត.ក អ្នកជំនាញទាំងអស់ត្រូវទទួលការតែងតាំងដោយអង្គជំនុំជម្រះដើម្បីធានាឱ្យមានឯករាជ្យភាព។ អ្នកជំនាញទាំងឡាយមានកាតព្វកិច្ចមកផ្តល់សក្ខីកម្មដោយមានភាពអព្យាក្រិត និងភាពពិតត្រឹមត្រូវខ្ពស់បំផុត ហើយការតវ៉ាផ្សេងៗចំពោះភាពលម្អៀងនៃសាក្សីដែលត្រូវកោះហៅមកធ្វើជាអ្នកជំនាញ គឺជាបញ្ហាមួយដែលពាក់ព័ន្ធនឹងការវាយតម្លៃលើភស្តុតាងដែលបុគ្គលនេះបានផ្តល់ ហើយការតវ៉ានោះមិនត្រូវធ្វើចំពោះការទទួលយកគាត់ជាអ្នកជំនាញឡើយ[២២]។ នៅក្នុងការកំណត់ថាតើបុគ្គលណាម្នាក់មានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីកោះហៅ

---

*រដ្ឋអាជ្ញា ទល់នឹង Stanislav Galić* សេចក្តីសម្រេចពាក់ព័ន្ធនឹងសាក្សីជំនាញ Ewa Tabeau និង Richard Philipps អង្គជំនុំជម្រះសាលាដំបូង (IT-98-29-T) ចុះថ្ងៃទី ០៣ ខែ កក្កដា ឆ្នាំ ២០០២។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Taylor* សេចក្តីសម្រេចលើពាក្យសុំរបស់ក្រុមមេធាវីការពារក្តីស្នើសុំដកភស្តុតាងសាក្សីជំនាញ Corinne Dufka ដែលរដ្ឋអាជ្ញាបានស្នើសុំ ឬ បើមិនដូច្នោះទេ កម្រិតវិសាលភាពនៃភស្តុតាងនេះ និងសេចក្តីសម្រេចលើសំណើសុំរបស់រដ្ឋអាជ្ញាឱ្យចេញសេចក្តីសម្រេចជាបន្ទាន់ (SCSL-03-1-T) ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៨ កថាខណ្ឌ ១២ (យល់ឃើញថាអ្នកជំនាញត្រូវមាន "ចំណេះដឹងឯកទេសពាក់ព័ន្ធ ដែលទទួលបានតាមរយៈការអប់រំ បទពិសោធន៍ និងការបណ្តុះបណ្តាលនៅក្នុងវិស័យជំនាញដែលបានស្នើសុំ ដើម្បីមានគុណវឌ្ឍិជាអ្នកជំនាញ")។ "ដីកាសម្រេចលើសំណើសុំអ្នកជំនាញបន្ថែម" របស់ ក.ស.ច.ស ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៩ ឯកសារលេខ D140/3 កថាខណ្ឌ ១៤។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Akayesu* សេចក្តីសម្រេចលើញត្តិរបស់ក្រុមមេធាវីការពារក្តី ស្នើសុំឱ្យជនជាប់ចោទចូលខ្លួនជាសាក្សីជំនាញ អង្គជំនុំជម្រះសាលាដំបូង (ICTR-96-4-T) ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៨។

២១ សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារ ដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាលដំបូងនៃសំណុំរឿង ០០២/០១ ឯកសារលេខ E185 ចុះថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ កថាខណ្ឌ ២៨ (សម្រេចថា វិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលជាស្ថាប័នឯករាជ្យ និងមិនរកប្រាក់ចំណេញ បំពេញការងារចងក្រងឯកសារស្តីពីឧក្រិដ្ឋកម្មសម័យខ្មែរក្រហម ក្នុងការទទួលបានឯកសារ ការធ្វើបណ្ណសារ និងការរក្សាទុកឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យ មានភាពអាចឱ្យជឿជាក់បាន)។

២២ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Vojislav Šešelj* សេចក្តីសម្រេចលើឋានៈរបស់អ្នកជំនាញ Reynaud Theunens របស់អង្គជំនុំជម្រះសាលាដំបូង (IT-03-67-T) ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ ("សេចក្តីសម្រេចលើឋានៈរបស់អ្នកជំនាញ Reynaud Theunens") កថាខណ្ឌ ២៨-២៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Nahimana, Barayagwiza* និង *Ngeze* សាលដីកា អង្គជំនុំជម្រះតុលាការកំពូល (ICTR-99-52-A) ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ("សាលដីកាលើរឿងក្តី *Nahimana, Barayagwiza* និង *Ngeze*") កថាខណ្ឌ ១៩៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Brdanin* សេចក្តីសម្រេចលើសារណារបស់រដ្ឋអាជ្ញា ស្តីពីសេចក្តីប្រកាសរបស់សាក្សីជំនាញ Ewan Brown អង្គជំនុំជម្រះសាលាដំបូង (IT-99-36-T) ចុះថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០០៣ ទំព័រ ៥ (ជាភាសាអង់គ្លេស)។

ជាអ្នកជំនាញនោះ អង្គជំនុំជម្រះអាចពិនិត្យមើល*ប្រវត្តិរូបសង្ខេប* អត្ថបទ ស្នាដៃបោះពុម្ពផ្សាយ ឬព័ត៌មានផ្សេងៗទៀតរបស់បុគ្គលរូបនេះ ពាក់ព័ន្ធប្រធានបទជំនាញដែលត្រូវការ រួមទាំងតួនាទីពីមុន និងបច្ចុប្បន្នរបស់អ្នកជំនាញដែលបានស្នើ[២៣]។

១៦. អនុលោមតាមយុត្តិសាស្ត្រអន្តរជាតិ សាក្សីជំនាញមានតួនាទីជួយបំភ្លឺដល់អង្គជំនុំជម្រះលើបញ្ហាបច្ចេកទេសជាក់លាក់ផ្សេងៗ ដែលទាមទារនូវចំណេះដឹងពិសេសនៅក្នុងវិស័យជាក់លាក់មួយ[២៤]។ សាក្សីជំនាញជួយបញ្ជាក់បំភ្លឺ និយាយជាបរិបទរួម ឬផ្តល់ការជួយជ្រោមជ្រែងបន្ថែមសម្រាប់ឱ្យអង្គជំនុំជម្រះវាយតម្លៃលើភស្តុតាង ប៉ុន្តែពុំផ្តល់សក្ខីកម្មលើអង្គហេតុទាំងឡាយដែលមានការតវ៉ាដូចជាការផ្តល់សក្ខីកម្មរបស់សាក្សីលើអង្គហេតុឡើយ[២៥]។ សាក្សីជំនាញមិនអាចផ្តល់មតិយោបល់លើបញ្ហាអង្គហេតុស្នូលនានានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់ជនជាប់ចោទឡើយ ដោយហេតុថា មានតែអង្គជំនុំជម្រះប៉ុណ្ណោះ ដែលមានសមត្ថកិច្ចសម្រេចសេចក្តីតាមផ្លូវតុលាការលើបញ្ហាទាំងនេះនៅក្នុងរឿងក្តី[២៦]។ ផ្ទុយមកវិញ សាក្សីលើអង្គហេតុផ្តល់សក្ខីកម្មអំពីបទល្មើសទាំង

---

[២៣] "សេចក្តីសម្រេចលើឋានៈរបស់អ្នកជំនាញ Reynaud Theunens" កថាខណ្ឌ ២៨។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Dragomir Milošević* សេចក្តីសម្រេចលើសាក្សីជំនាញរបស់ក្រុមមេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូង (IT-98-29/1-T) ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ ៦។

[២៤] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Karemera* សេចក្តីសម្រេចលើញត្តិរបស់ Joseph Nzirorera ស្នើសុំកម្រិតវិសាលភាពនៃសក្ខីកម្មរបស់សាក្សីជំនាញ Alison des Forges និង André Guichaoua អង្គជំនុំជម្រះសាលាដំបូង (ICTR-98-44-T) ចុះថ្ងៃទី ២១ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ ៣។

[២៥] សាលដីកាលើរឿងក្តី *Nahimana, Barayagwiza* និង *Ngeze* កថាខណ្ឌ ៥០៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Stanišić and Župljanin* សំអាងហេតុជាលាយលក្ខណ៍អក្សរនៃសេចក្តីសម្រេចផ្ទាល់មាត់របស់អង្គជំនុំជម្រះសាលាដំបូង ដែលទទួលយក Dorothea Hanson ជាសាក្សីជំនាញ អង្គជំនុំជម្រះសាលាដំបូង (IT-08-91-T) ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០០៩។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Semanza* សាលដីកា អង្គជំនុំជម្រះតុលាការកំពូល (ICTR-97-20-T) ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៥ កថាខណ្ឌ ៣០៤។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Akayesu* សាលក្រម អង្គជំនុំជម្រះសាលាដំបូង (ICTR-96-4-T) ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ១៤៦។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Zigiranyirazo* សាលក្រម អង្គជំនុំជម្រះសាលាដំបូង (ICTR-01-73-T) ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៨ កថាខណ្ឌ ១២០ កថាខណ្ឌ ១៤៨ (កត់សម្គាល់ឃើញថាសាក្សីជំនាញពុំអាចផ្តល់សក្ខីកម្មអំពីអំពើ និងការប្រព្រឹត្តរបស់ជនជាប់ចោទបានឡើយ លើកលែងតែសាក្សីជំនាញទាំងនេះមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីអង្គហេតុផងដែរ)។

[២៦] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Sagahutu* សេចក្តីសម្រេចលើការជំទាស់របស់រដ្ឋអាជ្ញាចំពោះសាក្សីជំនាញ Lugan និង Strizek, អង្គជំនុំជម្រះសាលាដំបូង (ICTR-00-56-T) ចុះថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៨ កថាខណ្ឌ ១៣។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bizimungu* អង្គជំនុំជម្រះសាលាដំបូង (ICTR-99-50-T) ចុះថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ១២។

ឡាយ ដែលត្រូវបានចោទប្រកាន់លើជនជាប់ចោទ[២៧] ហើយអាចបញ្ចេញមតិយោបល់ត្រឹមតែអ្វីដែលចេញមកពីបទពិសោធន៍ផ្ទាល់ខ្លួនតែប៉ុណ្ណោះ។ សក្ខីកម្មរបស់សាក្សីលើអង្គហេតុ កម្រិតត្រឹមតែអ្វីដែលខ្លួនបានដឹងឮ បានឃើញ ឬបានឆ្លងកាត់ដោយផ្ទាល់តែប៉ុណ្ណោះ[២៨]។

## ៤.២. ផ្នែកសម្រេចសេចក្តី

១៧. អង្គជំនុំជម្រះសាលាដំបូងជឿជាក់ថា សាស្ត្រាចារ្យ David CHANDLER មានគុណវឌ្ឍិជាអ្នកជំនាញម្នាក់ ដោយផ្អែកទៅលើការបណ្តុះបណ្តាល និងចំណេះដឹងឯកទេសរបស់គាត់ ដែលទទួលបានតាមរយៈការស្រាវជ្រាវ និងបទពិសោធន៍ជាច្រើននៅក្នុងវិស័យជំនាញដែលបានស្នើសុំ។ គាត់បាននិពន្ធសៀវភៅមួយចំនួនពាក់ព័ន្ធទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យ និងមន្ទីរ ស២១ និងត្រូវបានអង្គជំនុំជម្រះសាលាដំបូងកោះអញ្ជើញធ្វើជាអ្នកជំនាញនៅក្នុងសំណុំរឿង ០០១។ ខុសពីសំណុំរឿង ០០១ ពេលដែលសាស្ត្រាចារ្យ CHANDLER បានផ្តល់សក្ខីកម្មក្នុងរយៈពេលយ៉ាងយូរពាក់ព័ន្ធនឹងប្រតិបត្តិការប្រចាំថ្ងៃនៅមន្ទីរ ស២១ សក្ខីកម្មរបស់គាត់នៅក្នុងសំណុំរឿង ០០២/០១ ត្រូវបានស្នើសុំដោយសំខាន់ដើម្បីធ្វើការវិភាគអំពីគោលនយោបាយនានាដែលបានបង្កើតមន្ទីរ ស២១ និងគោលបំណង និងមុខងារសំខាន់របស់មន្ទីរសន្តិសុខនានា (ជាពិសេសមន្ទីរ ស២១) នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[២៩]។ អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាទៅលើការជំទាស់ជាក់លាក់ និងដែលមានហេតុផល ចំពោះសក្ខីកម្មរបស់គាត់ ដោយសារតែទំនាក់ទំនងរបស់គាត់ជាមួយនឹងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅពេលធ្វើការវាយតម្លៃលើសក្ខីកម្មរបស់គាត់។

១៨. ទោះបីជាពិចារណាឃើញថា លោក Philip SHORT និងអ្នកស្រី Elizabeth BECKER មានចំណេះដឹងឯកទេសនៅក្នុងវិស័យជំនាញដែលបានស្នើឡើង ដោយសារតែការស្រាវជ្រាវ និងការបោះពុម្ពផ្សាយសៀវភៅនានាស្តីពីសម័យកាលពាក់ព័ន្ធក៏ដោយ ក៏អង្គជំនុំជម្រះកត់សម្គាល់ឃើញ

---

[២៧] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Bizimungu* សេចក្តីសម្រេចលើភាពអាចទទួលយកបាននៃសក្ខីកម្មអ្នកជំនាញបណ្ឌិត Binaifer Nowrojee អង្គជំនុំជម្រះសាលាដំបូង (ICTR-99-50-T) ថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៥ កថាខណ្ឌ ១៣។

[២៨] រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Ngirumpatse* សេចក្តីសម្រេចលើ "ញត្តិរបស់ក្រុមការពារក្តីលោក Ngirumpatse សុំឱ្យដកសក្ខីកម្មសាក្សី GFJ និងឯកសារដែលពាក់ព័ន្ធ" អង្គជំនុំជម្រះសាលាដំបូង (ICTR-98-44-T) ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ១ និង ៤។

[២៩] *ប្រវត្តិរូបសង្ខេប*របស់លោក David Chandler, E215.1 ។

ថា ជារួម ពួកគាត់ត្រូវបានភាគីធ្វើការស្នើសុំឱ្យមកផ្តល់សក្ខីកម្ម ដោយសារតែចំណេះដឹងផ្ទាល់ខ្លួនរបស់ពួកគាត់អំពីអង្គហេតុនានា ពាក់ព័ន្ធទៅនឹងសម័យកម្ពុជាប្រជាធិបតេយ្យ ទាំងតាមរយៈវត្តមានរបស់ពួកគាត់នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងពេលពាក់ព័ន្ធ ដែលត្រូវបានកំណត់នៅក្នុងសំណុំរឿង ០០២/០១ ឬតាមរយៈការធ្វើសម្ភាសន៍របស់ពួកគាត់ជាមួយនឹងមេដឹកនាំ ឬកម្មាភិបាលទាំងឡាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលរួមទាំង ជនជាប់ចោទ អៀង សារី និង ខៀវ សំផន ផងដែរ។ ហេតុដូច្នេះ ពួកគាត់ត្រូវបានកោះអញ្ជើញធ្វើជាអ្នកជំនាញ ទោះបីជាពួកគាត់អាចនឹងត្រូវចោទសួរអំពីអង្គហេតុទាំងឡាយដែលពួកគាត់បានដឹងដោយផ្ទាល់ ទាក់ទិននឹងសំណុំរឿង ០០២/០១ ក៏ដោយ។

**ដោយផ្អែកលើហេតុផលខាងលើ អង្គជំនុំជម្រះសាលាដំបូង ÷**

**តែងតាំង** លោក David CHANDLER លោក Philip SHORT និងអ្នកស្រី Elizabeth BECKER ធ្វើជាអ្នកជំនាញ ស្របតាមការចាត់តាំងដែលបានកំណត់នៅក្នុងសេចក្តីសម្រេចនេះ។

**សម្រេច** ថា បុគ្គលទាំងនេះអាចត្រូវបានចោទសួរអំពីរាល់បញ្ហាទាំងអស់ដែលពួកគាត់បានដឹង ឬដែលជាជំនាញរបស់ពួកគាត់ ពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ និង

**ចាត់** សហព្រះរាជអាជ្ញាឱ្យទទួលខុសត្រូវដឹកនាំការចោទសួរពួកគាត់នៅក្នុងតុលាការ អនុលោមតាមវិធាន ៩១ និង ៩១ *ស្ទួន* នៃវិធានផ្ទៃក្នុង។

**រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០១២**

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C E T C

**និល ណុន**